# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើត នាយកដ្ឋានពត៌មាន និងកិច្ចការអាស៊ាន ចំណុះក្រសួងអប់រំ យុវជន និងកីឡា

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងអប់រំ យុវជន និងកីឡា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

មាត្រា១ : ត្រូវបានបង្កើតនាយកដ្ឋានពត៌មាន និងកិច្ចការអាស៊ាន ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា២ : នាយកដ្ឋានពត៌មាន និងកិច្ចការអាស៊ានមានមុខងារ និងភារកិច្ចដូចខាងក្រោម :

-ទំនាក់ទំនងពត៌មានសាធារណៈ និងការផ្សព្វផ្សាយពត៌មានអប់រំ យុវជន និង កីឡា

www.pheakdeylaw.com

-គ្រប់គ្រងការងារ ពតិមានវិទ្យា (IT: InformationTechnology) និង សារគមនាគមន៍ ក្នុង វិស័យអប់រំ យុវជន និង កីឡា

-ទំនាក់ទំនងការងារអប់រំ យុវជន និង កីឡា ជាមួយក្រសួង-ស្ថាប័នជាតិ និង បណ្តាប្រទេស សមាជិកអាស៊ាន និង ស៊ីមីអូ ( SEAMEO : Southeast Asian Ministers of Education Organization ) ក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

មាត្រា៣ : នាយកដ្ឋាន ពតិមាន និង កិច្ចការអាស៊ាន ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន មួយរូប និង អនុប្រធាននាយកដ្ឋាន មួយរូប រឺច្រើនរូប តាមការចាំបាច់ ។

មាត្រា៤ : ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់នាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា៥ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

ភ្នំពេញថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៦

-ឯកសារ/កាលប្បវត្តិ

www.pheakdeylaw.com